


# បច្ចេកទេសបង្កាត់ពូជស្វាយចន្ទី



ស្រកីដូងរុំកន្លែងចិត



ថង់ប្លាស្ទិករុំភ្ជិត



បាវក្រចៅរុំភ្ជិត





ចិតមែកបន្តិចម្តងៗរហូតដល់ដើមចេញឫសមាំទាំ



កាត់ទុកដាំ

# បច្ចេកទេសបង្កាត់ពូជស្វាយចន្ទី

## ការជ្រើសរើសពូជដែលមានទិន្នផលខ្ពស់

ភាគច្រើននៃពូជដែលបានរំដោះដោយស្ថានីយ៍ស្រាវជ្រាវគឺមិនមានបញ្ហាអ្វីទេក្នុងការជ្រើសរើសពូជ។ កសិករអាចធ្វើការសង្កេតតាមដាននិងអាចធ្វើការជ្រើសរើសពូជដោយខ្លួនគាត់ដោយផ្ទាល់។ ការជ្រើសរើសគឺត្រូវដាក់ឈ្មោះផ្តល់នូវអត្តសញ្ញាណហើយបន្តធ្វើឱ្យមានចំនួនពូជនេះកើនឡើងច្រើន គួរតែធ្វើលើសរីរាង្គលូតលាស់របស់វាពោលគឺធ្វើតាមរយៈការបំបៅឬ ផ្សាំមែក។ យោងតាមការវិនិច្ឆ័យនេះយើងអាចធ្វើការជ្រើសរើសនៅលើដើមណាដែលបានផ្តល់ទិន្នផលខ្ពស់ និង មានលក្ខណៈដូចខាងក្រោមៈ

-រុក្ខជាតិមានការលូតលាស់លឿន មែកបែកសាខានិងស្រឡះល្អ

-ត្រូវមានកញ្ចុំផ្កាពី ១០-៣០ កញ្ចុំក្នុង ១ ម៉ែត្រការ៉េ។ ចំនួនកញ្ចុំផ្កាច្រើនគឺមានសក្តានុពលនៃទិន្នផល។

-ផ្កាទ្វេភេទដែលមានចំនួនពី ១០-៣០០។ ចំនួនផ្កាទ្វេរភេទច្រើន គឺបានទិន្នផលច្រើន។

-ទម្ងន់គ្រាប់ ជាមធ្យម ៧ ក្រាម ក្នុងមួយគ្រាប់

-រុក្ខជាតិត្រូវចាប់ផ្តើមចេញផ្កា (មករា-កុម្ភៈ) ឬ (កុម្ភៈ-មីនា)ដើម្បីជៀសផុតពីពួក **មូសតែ។** រដូវ ចេញផ្កាមានរយៈពេលខ្លី (១-៣ខែ)។

-ដើមឈើត្រូវតែមានភាពធន់ទ្រាំនឹងការបំផ្លាញសត្វល្អិត និង ជំងឺ

-ភាគរយនៃទិន្នផលគ្រាប់ត្រូវតែច្រើនជាង ២៨ % នៃគ្រាប់ទាំងមូល

-ដើមឈើពេញវ័យល្អ (អាយុ ១៥ឆ្នាំ ឬលើសនេះ) ត្រូវតែផ្តល់ផលពី ១៥-២៥ គ.ក្រ។

-ចំពោះដើមដែលដាំនៅដាច់តែឯងផ្តល់ផលប្រហែលជាក្នុងមួយដើម ផ្តល់ផលបាន ៥០-៦០ គ.ក្រ។

## ការបន្តពូជតាមសរីរាង្គលូតលាស់

ភាគច្រើននៃចំការស្វាយចន្ទីចាស់ៗ ត្រូវបានបង្កើតឡើងដោយការដាំកូនដែលបណ្តុះពីគ្រាប់ ។ រុក្ខជាតិដែលបានមកមិនមានលក្ខណៈជាឯកសណ្ឋានភាព ដូច្នេះដើម្បីទទួលបានជោគជ័យក្នុងបញ្ហានេះ គេត្រូវធ្វើការបំ-បៅ ដោយធ្វើការជ្រើសរើសមែកពូជដែលមានគ្រាប់ធំហើយទិន្នផលជាមធ្យម ច្រើន ជាង ១០ គ.ក្រ ក្នុងមួយដើមក្នុងមួយឆ្នាំ អាចជ្រើសរើសសម្រាប់ការបង្កើនចំនួនស្វាយចន្ទីនេះ។

វិធីសាស្ត្រផ្សាំ និងបំបៅសរីរាង្គខ្ចី គឺជាវិធីសាស្ត្រពីរដែលអាចធ្វើបានសម្រាប់បង្កើននូវចំនួនកូនរុក្ខជាតិដោយប្រើប្រាស់សរីរាង្គលូតលាស់។ ចំណែកការផ្សាំ និង បំបៅ អាចធ្វើបានដោយកសិករធម្មតា។ វិធីសាស្ត្រទាំងពីរនេះ គឺមានការចំណាយច្រើនជាង ការដាំដោយគ្រាប់ ហើយត្រូវមានការអនុវត្តន៍ និង ការគ្រប់គ្រងរោងបណ្តុះឱ្យបានល្អ។

### ក. វិធីសាស្ត្រសាកមែក

ជ្រើសរើសមែកពូជណាដែលពេញវ័យល្អមានទំហំប្រហែលម្រាមដៃ ត្រូវមានប្រវែង ៣០-

៤០ ស.ម ពីខាងចុងនៃមែក ។ មែកនោះត្រូវចិតយកសំបកឈើ ដោយក្រឡឹងជុំវិញមែកប្រវែង ២,៥ ស.មយកវាចេញដោយថ្នមៗបន្ទាប់មកកោសរំអិលវាចេញ ។ បំណែកស្រកីដូងម៉ត់ ឬអាចម៍រណាដែលផ្សើមរួចដាក់ឱ្យចំមុខដែលចៀវសំបកដែលមានទទឹង ១០ ស.ម ដោយប្រើបន្ទះប្លាស្ទិក (គេប្រើនៅរដូវប្រាំង) ឬ ក្រណាត់កូតុងស្តើងៗ ហើយផ្សើមកន្លែងចងនោះ ។

ឫសនឹងលេចចេញក្នុងកំឡុងពេលពី ៤៥-៦០ ថ្ងៃ ក្រោយពេលផ្សាំ។ ពេលឫសដុះចេញ ដកប្លាស្ទិកចេញ ហើយកាត់ភាគខ្លះនៅគល់ ។ ក្រោយរយៈពេលមួយអាទិត្យ ប្រសិនបើស្លឹកដែលសាកនោះ នៅមានពណ៌បៃតង យើងអាចកាត់មែកនោះចេញមកត្រៀមដាំបាន។ ដើមដែលដុះឬសចេញមកនេះរក្សាទុកនៅក្នុងរោងបណ្តុះដោយមានម្លប់ ៥០ភាគរយ។ ការដាំដុះដោយសាករបៀបនេះ គប្បីថែទាំឱ្យបានត្រឹមត្រូវល្អ ជៀសវាងការបំផ្លាញពីកត្តាផ្សេងៗដល់ឬសខ្ចី ដែលទើបតែដុះថ្មី។



ជ្រើសរើសមែកល្អ





ចិតសំបកខាងក្រៅមែក



ស្រកីដូងរុំកន្លែងចិត



ចងប្លាស្ទិករុំភ្ជិត



បាវក្រចៅរុំភ្ជិត





ចិតមែកបន្តិចម្តងៗរហូតដល់ដើមចេញឬសមាំទាំ



កាត់ទុកដាំ